Khmer Story Lovers

ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ ច័ន្ទ ពុធ សៅរ៍



អ្នកប្រែសម្រួលៈ អ.គីមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
« មាតុភូមិ »
ភ្នំពេញ
លេខ ២

លុះក្រឡេកមើលទៅឃើញពួកពលសេនាជំរុំកាំបិតមាសមានគ្នាជាង៤០០នាក់ ម្នាក់ ១ មានមាឌមាំមួននោះជាគ្មានអ្នកក្លាហាន តែគេមានគ្នាច្រើនណាស់ ស៊ីឈីង ជាមនុស្សដែលមានចិត្តរឹងរូសណាស់ ម៉្យាងទៀតអម្បាញ់មិញនេះ ចូវមុហាក់មានសំដីមិនសូវគប្បីចំពោះគាត់ផងក៏នឹកថា ឯងកុំមើលងាយថាយើង ២នាក់ប្តីប្រពន្ធខ្លាចឯងនោះ នឹកស្មានថាឯងអាចធ្វើអ្វីពួកយើងបានឬ? គាត់នៅតែមានទឹកមុខញញឹមជានិច្ច លើកដៃចង្អុលទៅគុម្ពោតព្រៃមួយនៅខាងកើតដោយពោលថាៈ

– ខ្ញុំបាទមានពាក្យមួយមាត់ទៀត ចង់ពិគ្រោះជាមួយប្អូនចូវផ្ទាល់តែម្តង សូមលោកប្អូនអញ្ជើញទៅខាងណោះបន្តិច ។

–ចូវមុតបជាងវិញ :

–នៅទីនេះសុទ្ធតែបងប្អូនរបស់ខ្ញុំទេ មានរឿងអ្វី គួរតែ . . .

មិនទាន់ចាំងពោលចប់ផង ស្រាប់តែដៃឆ្វេងគាត់គឹងផ្ទះ ដោយត្រូវស៊ីឈីងលូកមកកៀបដីពចកដៃជាប់ ធ្វើឲ្យគាត់ស្ពឹកខ្លួនអស់មួយចំហៀង ហើយដៃស្តាំក៏ទន់កំរើកលែងរួចដែរ ។ ពេលនេះចូវមុខ័ងផងក៏យផង ព្រោះពាប់តាំងពីស៊ីឈីងនិងវុនយូព័រនាក់ប្តីប្រពន្ធលេចចេញមក គាត់តែងតែមានការប្រុងប្រយ័ត្នមិនហ៊ានធ្វេសប្រហែស: ទ តែស៊ីឈីងពិតជាមានការហេតុការរហ័សរហួនដូចផ្លេកបន្ទោរ មិន

ដិតជាគេប្រើស្បៀតអីផង ស្រាប់តែចាប់កៀបកដៃខ្លួនជាប់តែម្តង ។ ស៊ុណីង ស្រែកខ្លាំងៗ ថា:

-បើលោកប្អូនចូវយល់ព្រមទៅពិគ្រោះគ្នា ជាការប្រសើរណាស់ ។

ពោលចប់, គាត់បែរទៅរកវុនយូបន្តទៀតថា:

-អូន ! បងនិងលោកប្អូនចូវទៅនិយាយគ្នាខាងណោះបន្តិចត្រឡប់មកវិញហើយ សូមអូនទៅចាំទីនេះសិនចុះ ។

ពោលហើយនាំចូវមុដើរចេញទៅ, វុនយូឆ្លើយថា:

-សូមបងអញ្ជើញចុះ !

អ្នកទាំង២គោរពគ្នាទៅវិញទៅមកដូចកៀវ . សេនាទាំងអស់នៃជំរំកាប៊ិតមាសឃើញគេនាំចូវមុទៅជាមួយយ៉ាងរីករាយ ហាក់ដូចជាគ្មានបំណងអាក្រក់អ្វីទេ ដោយប្រពន្ធគេនៅទីនេះស្រាប់ផងគ្មានអ្នកណានឹកស្មានទាល់តែសោះថា កម្រិតវិជ្ជាដូចចូវមុនេះអាចធ្លាក់ក្នុងកណ្តាប់ដៃគេដោយស្ងាត់ស្ងៀមដូច្នេះសោះ ។ ឯស៊ុណីងចាប់ជីពចរដៃចូវមុំនាំដើរទៅតែតែលឿនឡើងៗ, ចូវមុឲ្យតែហានយឺតបន្តិចច្បាស់ជាដួលផ្កាប់មុខពុំខាន ។ ម្ល៉េះហើយបេះកែងចំប្រឹងរត់តាមលុះត្រាតែចូលក្នុងគុម្ពោតព្រៃ ។ ស៊ុណីងលែងដៃសើច ពោលថា:

-លោកប្អូនចូវ .

ចូវមុតំហកទាំងក់ហឹងថា

-ឯងធ្វើអ្វី ?

គាត់លូកដៃស្តាំច្បាមទ្រូងស៊ុណីងយ៉ាងរហ័ស ។ ស៊ុណីងលើកដៃឆ្វេងគ្រវាសទៅម្ខាងចាប់ដៃគាត់ទាំងពីរមួលទៅក្រោយខ្នង ។ ចូវមុភ័យជាអតិបរមាលើកជើងឆ្វេងធាក់ទៅក្រោយ ។ ស៊ុណីងសើចចំអក:

-កុំច្រឡោតខ្លាំងពេក !

រំពេចនោះចូវមុទទួលអារម្មណ៍ដោយជីពចរពើរកន្លែងឈឺស្ពឹក ជើងដែលទើបលើកផុតពីដីក៏ទន់ធ្លាក់ចុះមកវិញ ។ ម្តងនេះគាត់មានជើងតែ១គត់អាចទប់ខ្លួនបាន ហេតុនេះគាត់មិនហ៊ានលោតធាក់ទៀតទេ គាត់មានទឹកមុខក្រហមឆ្អិនស្រែកតំហកថា:

-ឯង···ឯង ..ឯង...

ស៊ីឈ័ងមិនរវល់នឹងការទឹងច្រឡោតរបស់គាត់ឡើយសួរថាៈ

- វត្ថុដែលឯងយកបានពីរូតាវ៉ឺនោះ ខ្ញុំចង់សុំខ្ចីមើលបន្តិច សូមលោកប្អូនអញ្ជើញយកចេញមក !

ចូវមុតបវិញថា :

- វត្ថុនោះមានមែនតែមិនមែននៅក្នុងខ្លួនយើងទេ បើឯងចង់មើលយើងត្រូវតែត្រឡប់ទៅខាងណោះវិញ ។

គឺគាត់ចង់ឆ្លៀតបញ្ឆោតស៊ីឈ័ងឲ្យត្រឡប់ទៅកាន់កន្លែងក្នុកក្បៀនវិញ ដើម្បីបញ្ជាឲ្យពួកពលសេះឡោមវាយសម្រុក ។ ទោះជាស៊ីឈ័ងនឹងវ័យមានវិជ្ជាខ្ពង់ខ្ពស់យ៉ាងណាក៏មិនអាចទប់ទល់បានដែរ ។ ស៊ីឈ័ងសើចហាសៗ, ពោលថាៈ

- យើងជឿឯងមិនបានទេ សុំឆែកខ្លួនឯងបន្តិចចុះ ។

ចូវមុគំហកទៀតថា :

- ចង់ឆែកយើងបែបហ្នឹង តើឯងទុកយើងជាមនុស្សបែបណា ?

ស៊ីឈ័ងមិនខ្វល់តបលូកដៃដោះស្បែកជើងធ្ងន់របស់គាត់ភ្លាម ។ ចូវមុស្រែកយ៉េស ! ស៊ីឈ័ងឆ្វេះបានកូនកញ្ចប់មួយពីក្នុងស្បែកជើង គឺកញ្ចប់ដែលគាត់យកពីបន្ទាយរូតាវ៉ឺនោះឯង ។ ចូវមុផ្តាំងសួរ :

- ម៉េចគេដឹងហ្នឹង ! គេឃើញយើងលាក់ក្នុងហ្នឹង ឬ ?

ការពិតគឺនៅពេលស៊ីឈ័ងតាមកាត់តែ, គាត់ចោលភ្នែកមើលជើងធ្ងន់មួយដែលបង្កលឲ្យស៊ីឈ័ងសង្ស័យជាខ្លាំង បានជាចាប់ផ្តើមដោះស្បែកជើងធ្ងន់គេមុន ។

ចូវមុភ័យស្ងន់ចង់ស្រែកហៅគេជួយ តែស៊ីឈ័ងពោលមុន :

- ឯងក្បត់លោកតាយជ៉ាំហើយ ។ តិតមើល ! គួរឲ្យយើងលើករឿងនេះលាតត្រដាងចំពោះមុខនាយសេនាធំទាំងអស់ ឬសុខចិត្តទទួលទារុណកម្មតាមច្បាប់ទម្លាប់ ?

ចូវមុមិនទាន់បានតទល់ ក៏ប្រថុយសួរៈ

- ម៉េចឯងដឹង ?

ស៊ីឈីនគិតតាមសំរួល.

មិនបាច់ព្រួយទេ យើងដឹងអស់រលីងហើយ ។

ពោលដូច្នេះហើយតែក្នុងចិត្តនឹកថា:

- តាមស្ដាប់សំដីគេនិយាយពីរឿងនែកផ្ទះលក់ទំនិញដូចជា គ្មានជឿជាក់ស្រុង, តែពេលនេះឃើញវត្ថុនៅក្នុងខ្លួនឯងហើយ ពិតជាឯងលោកយកប្រយោជន៍ម្នាក់ឯង ។

គិតរួចគាត់ឆ្លើយវិញ :

- នាយដំរីកាំបិតមាសមានប្រាជ្ញាណាស់, ឯងលាក់ទឹងយើងមិនបានផង, ចង់លាក់ទឹងគាត់ទៀតឬ ?

ពោលសិនមិនទាន់ចប់ស្រាប់តែលាន់សំណើចក្អាកក្អាយមកពីនាយព្រហ្មកាំងសម្ដេងខ្វះ:

-សូមអរគុណចំពោះសេចក្ដីសរសើររបស់លោកស៊ីតិចហ្វាយ ។

ឱ្ះ! បុរសពាក់លេចរូបកើនដល់ក្បែរព្រៃស្រេច ។ នៅមុខគេបង្អស់គឺលោកនាយដំរីមាសឈាមកេនហ្វុងយី , អ្នកទី២គឺហ្វុនជិនវ៉ិនជនចំណាស់អ្នកសប្ដុំឈ្មោះម៉ូខុន ។ កាលអានហ្វុងយីបញ្ជាសេនាទៅរកវ៉ូតាវ៉ីអ៊ីនោះឥតបានបញ្ជាក់ថា ចាត់ត្មាតមកជួបប្ដុំទង់ណាទេ, ពេលនេះគាត់ចេញមកខ្លួនឯងធ្វើឲ្យចូវមុកភ័យលើសដើម ខ្លាចត្រូវទោសដល់ជីវិត ។ ដល់ភ័យខ្លាំងពេកស្រាប់តែស្រែកទាំងទឹកថា :

- លោកបងកាន ! វត្ថុ ... វត្ថុនោះជណ្ដើមយកទៅហើយ ។

កានហ្វុងយីមិនរវល់ស្ដាប់ បែរមកគោរពស៊ីឈីន :

- លោកមេក្លូមិជ្ឈានល្បីសុសសាយពេញពិភពគុន ខ្ញុំបាទត្រកូលកានសុំស្ញើកសរសើរដោយស្មោះ ។ ថ្ងៃនេះមានសំណាងណាស់ដោយបានជួបលោកប្រុសលោកស្រី ហេតុនេះសុំអញ្ជើញទៅសំរាកក្នុងដំរីខ្ញុំពីរបីថ្ងៃសិន ក្រែងខ្ញុំបាទមានពេលមើលលោកបង្ហាញស្នៀតគុនខ្លះ ។

ស៊ីឈីនក្រឡេកឃើញលោកនាយដំរីផុះពុកមាត់ស្រមូម កងតាបកន្ទិញមិនសមនេះពោលពាក្យពេះដូច្នេះសោះ ។ គេមិនសើរើរឿងជណ្ដើមក្បូនកញ្ចប់បែរជាអញ្ជើញទៅលេងដំរី ។ ស៊ីឈីននឹកថា ពីរបីចូលដល់ដំរីកាំបិតមាសហើយ យើងគាចចេញវិញដោយស្រួលទេ ។

គិតដូច្នេះហើយ គាត់ញាក់កញ្ចប់ក្នុងថង់អាវ រួចតំនាប់តបវិញពោលថា :

- សូមអរគុណលោកដែលមិនបានយកជីវិតខ្ញុំ ...

ស្រាប់តែបងជេតប្រែក្រសេចក្រសោះ ស្នាមស្រស់ស្រាយក៏បាត់ពីលើភក្ត្រព្រមទាំងគំរាម!

-ដាក់ក្បាលនេះចុះសិន !

កាយវិការអ្នកសម្លូតហាក់ស៊ីឈីនហាក់ដាក់គាត់ដោយចិត្តរីងចូល ដល់មួខុនហុចវត្ថុដល់ដៃពោលថា :

- ឲ្យឯងចុះ !

មួខុនមិនបានជាតកណ្ដាលប្រកែកប្រញាប់ប្រញាល់ស្រាប់តែស្ទុះដៃរបូតដាវទៅ ... ។ ស៊ីឈីនដណ្ដើមដាវបានហើយលូកចុចដីតាមអ្នកសម្លាប់ហ៊ីមហាក់ដំហក :

-ដាក់កញ្ចប់នេះចុះសិន !

មួខុនភ្ញាក់ព្រើតតែមុខងាកស ស្លាចជំនួលរើតថាហើយ គាត់ត្រូវផ្ទេរដៃបោះកញ្ចប់តូចទៅវិញ ។ ហ៊ុនជិនវូសើច :

-អស្ចារ្យមែន !

ស៊ីឈីនចាប់កញ្ចប់តូចមិនទាន់បានដល់ជិនវូឡេ ។ ជិនវូបញ្ចេញស្នៀតកាំបិតពាយសម្រុកទៅយ៉ានវហ៊ស, ស៊ីឈីនរញ្ជួយដាវចាក់ឈើបតម្រង់ក្បាលជិនវូ។ គាត់ប្រើកាំបិតអាចកាប់ត្រូវជើងស៊ីឈីនតែស៊ីឈីនក៏អាចកាប់ដាច់ក្បាលហ៊ុនជិនវូវិញដែរ, ម្ល៉ោះហើយតានហ៊ុនយ៉ីមិនបណ្ដោយយូរក៏ស្រែកថា :

- សូមអភ័យទោស !

ស៊ីឈីនចាក់ទៅមុខដដែល, ជិនវូត្រូវក្ដីទុក្ខខ្លួនគេចកែ្តករទីតាំងស្លាប់ ។ ក្រោយនោះគាត់ទទួលអារម្មណ៍ត្រជាក់ស្រឹបត្រង់ថ្ពាល់ខាងឆ្វេងហើយឈឺផង, ដាវស៊ីឈីនឈប់ស្ងៀមត្រឹមនោះទៅ រួចភ្លាមប៉ុកគីស៊ីឈីនលាស់ថ្ងៃដាវឆ្កឹះកញ្ចប់តូចទម្លាក់ក្នុងដៃគាត់វិញ យ៉ានវហ៊ស ហើយទុកដាវពោលព្រងើយ:

- អត់ទោស !

បន្ទាប់ពីនោះគាត់ថយក្រោយពីរជំហាន, ហ៊ុនជិនវូលើកដៃស្ទាបថ្ពាល់មុខក្រហមដោយអៀនខ្មាសពេក ។ តានហ៊ុនយ៉ីដោះអាវចេញដកកាំបិតពីក្រោយខ្នងតាំងផ្តេកក្រោមស្មើព្រះភក្ត្រ សបដាក់កាំបិតមាសដ៏មុតក្រៃលែងមែន ។ តានហ៊ុនយ៉ីដាក់កាំបិតមាសពីមុខខ្លួនពោល:

- លោកស៊ីមានវិជ្ជាខ្ពស់លើសលុបគួរស្ញើចសរសើរណាស់, សូមមេត្តាជួយបង្ហាត់បង្ហាញខ្ញុំផង !

ស៊ីឈីនសើចៈ

- អូ! សំណាងណាស់បានជួបលោកម្ចាស់ដាវកាំបិតមាស,

ពោលចប់គាត់បោះកញ្ចប់តូចចេញទៅភ្លាម ។ អ្នកវាំងអស់ស្រឡាំងកាំង ព្រោះពុស្សូរឈប់ ! កញ្ចប់ហើរទៅប៉ះមែកឈើមួយ ដាវស៊ីឈីនរត់តាមក្រោយដោតជាយកញ្ចប់ភ្ជាប់នឹងមែកឈើ ឥតឲ្យប៉ះពាល់ដល់វត្ថុក្នុងកញ្ចប់ផងទេ ។ កាយវិការនេះរហ័សដូចផ្លេកបន្ទោរ មិនចាញ់ស្នៀតវាយម្ជុននិងហ្វុនផិនប៉ូអម្បាញ់មិញទេ ។ ផុតពីស្រឡាំងកាំងគេងាកមកមើលស៊ីឈីនវិញ ឃើញគាត់កាន់ដាវខ្សែរលោនមួយស្រេច ហើយពោលខ្លាំងៗ :

- ទៅជួបនឹងកាំបិតមាសប្រហែលគួរមើលដែរ .... ល្អើយ! អ្នកណាឈ្មោះមួយស្នៀតអ្នកនោះបានកញ្ចប់លើមែកឈើជារង្វាន់ !

អានហ្វុនយីឃើញស៊ីឈីនវៃឆ្លាតហើយរហ័សរហួនក៏សរសើរម្តងទៀត

- លោកម្ចាស់ភូមិដ្ឋានពូកែដោះស្រាយមែន! សូមអញ្ជើញ!

អានហ្វុនយីឮថា ពុល្បីម្ចាស់ភូមិដ្ឋានសាំនស៊ូ ឈ្មោះស៊ីឈីនមិនក៏រយៈឈ្មោះវុនយូថាបេះគុនដាវខ្ពស់ ដូចមានកស្តុតាងដាក់ស្តែងអម្បាញ់មិញស្រាប់ ម្ល៉ោះហើយគាត់មិនហ៊ានធ្វេសប្រហែសទេ ពុភ្លាមយកកាំបិតកាប់រឹប ៗ បីផុនជាបន្តបន្ទាប់គ្នា ។ ស៊ីឈីនយល់ច្បាស់ជាស្នៀតដង្ហែ ក៏ ឈរស្ងៀមស្រែកថា :

- អញ្ជើញចូលមក :

ដល់ពេលនេះទើបអានហ្វុនយី លើកកាំបិតកាប់ជាំង រួបដាវមុខឡើងគ្រាប់សម្លុយរឹបទៀត ។ នេះជាវិជ្ជាគុនកាំបិតប្រចាំកាយម្ចាស់ជាំកាំបិតមាស ដែលមានចំនួន ៧៦ ស្នៀត ប្រែប្រួលមិនចេះចប់ ។ ស៊ីឈីនឥតញញើតឡើយ គាត់រង់កាត់ ឬលាស់ដាវទៅវាយសងវិញយ៉ាងមធ្យ័តៗ. បានប្រហែល ៣០ស្នៀតគាត់ហួចខ្ទេច បញ្ចេញស្នៀតគុនដាវវាយលុកយ៉ាងរហ័ស បណ្តាលឲ្យអានហ្វុនយីមើលលែងយល់ដឹកក័យស្ងួនខំគ្រវាសកាំបិតញាប់ស្មោការពារជីវិតសំខាន់ ។ មិនឲ្យម្ចាស់ភូមិដ្ឋានសាំនស៊ូចុចបាន ។

មួយសន្ទុះក្រោយពុធិន ' គឺផ្ទៃដាវកាប់ត្រូវកាំបិតរអិលជួប ! នេះជាស្នៀត «ទឹកហូរបណ្តោយស៊ឹង » លាមញ្ញអស្ចារ្យ ដែលអានហ្វុនយីអាចគៀសកាំបិតចេញកាប់សងវិញយ៉ាងឆាយ ។ ប៉ុន្តែ

ចំពោះស៊ីឈឹនដែលហ៊ានលើសការស្មាន គាត់មិនអាចធ្វើដូចម្ដេចបានឡើយ ព្រោះដាវស៊ីឈឹនរើលពី ខ្នងកាំបិតជ្រុះជិតប៉ះម្រាមដៃគាត់ទៅហើយ ។ អានហ្វុនយីភ្ញាក់ក្រញាងភ័យស្លាំងស្លេក នឹកថា ម្រាមដៃយើងទាំងបួនដាច់ធ្លាក់ក្រោមផ្ទៃដាវនេះឡូវហើយ !

អានហ្វុនយីភ័យផ្អើលមាត់រកដកកាំបិតលោតថយក្រោយមិនបាន ។ ប៉ុន្តែខណៈដែល គាត់រង់ចាំគ្រោះថ្នាក់នោះស៊ីឈឹនបែរជាបញ្ឈប់ដៃទប់មុខដាវជាប់មិនឲ្យប៉ះម្រាមទាំងបួន ហើយថយមួយជំហានក្រោយ ។ អានហ្វុនយីយល់ថាគូប្រយុទ្ធយោគយល់ខ្លួនណាស់ត្រូវតែទម្លាក់កាំបិតចុះចាញ់ ទើបគេហៅអ្នកក្លាហាន ។ ស៊ីឈឹនហាក់យល់ចិត្តនាយជំរំកាំបិតមាសបានជាបង្វិលដាវទៅទ្រ កាំបិតមិនឲ្យជ្រុះពីដៃអានហ្វុនយីព្រមទាំងពោលៈ

- យើងមានសមត្ថភាពស្មើគ្នាមិនងាយចាញ់ឈ្នះទេ ។

ពោលផងអង្រែនដាវឡើងថ្កល់កាំបិតមាសឲ្យងើបខ្ពស់ឡើងវិញផង ។ អានហ្វុនយីក្រេកអរហើយ រំភើបចិត្តណាស់ក្ដាប់ដងកាំបិតជាប់វិញ ហើយបន្ទន់កាយគោរពតាមស្ទៀកគុនចុងក្រោយបង្អស់ ពេល នោះ គាត់ភ្ញាក់ខ្លួននឹកឃើញប្រាជ្ញា ស៊ីឈឹនដែលរង់ចាំឲ្យគាត់បញ្ចេញស្ទៀកគុនកាំបិតគំរប់៧២ សិនទើប ព្រមឲ្យគាត់ចុះចាញ់ ។

ទាល់តែស្គាល់ស្ទៀកទាំងអស់ទើបស៊ីឈឹនសុខចិត្ត ព្រោះបើពុំនោះទេ គេវាយលុកតាំងពីដំបូងដៃ យកជ័យបានទៅហើយ ។ អានហ្វុនយីហួសបើគិតបែរជាហាមាត់ថ្លែងអំណរគុណចំពោះម្ចាស់ ភូមិឋានសាន់ស៊ូតែស៊ីឈឹនស៊កដាវទុកក្នុងស្រោមញាប់ដៃពោលមុនថា :

-ខ្ញុំបាទសុំលោកនាយជំរំធ្វើមិត្តតាំងពីថ្ងៃនេះទៅ ។ យើងមិនបាច់ប្រកួតប្រជែងគ្នាទេ, ថ្ងៃណា លោកបានទៅសានតុងសូមកុំភ្លេចចូលលេងផ្ទះខ្ញុំណា !

អានហ្វុនយីតបទាំងស្រងូត:

- បាទខ្ញុំមិនភ្លេចគុណលោកទេ ។

ពោលចប់គាត់លោតផ្លោះកម្រងដើមឈើលើកដៃផ្ទាក់ដាវយកកូនកញ្ចប់ ហើយកាន់ទាំងកាំបិត ទាំងកញ្ចប់តូចដើរតម្រង់ស៊ីឈឹនពោលបេះដោងគោរពៈ

- សូមជូនលោកម្ចាស់ភូមិឋាន .

ស៊ីឈឹនលើកដៃគោរពតបពោលធ្វើហ៊ៈ

- ថ្ងៃក្រោយសុំជួបគ្នាទៀត ។

រួចគាត់ងាកក្រោយបោះជំហានចេញទៅ , អានហ៊ុនយីស្រែកហៅ :

- ឈប់សិនលោក ! លោកខុកមុខខុកមាត់ឲ្យខ្ញុំប៉ុណ្ណេះខ្ញុំត្រេកអរណាស់ហើយ , ប្អូនទទួល កញ្ចប់តូចនេះជារង្វាន់តាមពាក្យសន្យា បើមិនដូច្នេះទេអ្នកផងដៀលខ្ញុំចោទខ្ញុំថា ធ្វើបុកបោកតាប មិនបានឡើយ ។

ស៊ុឈីនងាកមកញញឹម :

- លោកនាយជំរើយល់ច្រឡំហើយ ! ការសាកល្បងលើកនេះ មិនទាន់ដឹងចាញ់ឈ្នះព្រោះ លោកមិនទាន់បង្ហាញចំណេះអស់ពីខ្លួនឯណា ? ម្យ៉ាងទៀតនៅក្នុងកញ្ចប់នេះមិនទាន់ពិតថាមានវត្ថុជាទី ប្រាថ្នានៃយើងទេ , តាមខ្ញុំយល់គឺយើងចាញ់បោកគេហើយ ។

អានហ៊ុនយីបើកភ្នែកមូលក្រឡង់សួរ :

- ឥតមានវត្ថុដែលយើងស្វែងរកទេឬ ?

ពោលបណ្ដើរស្រាយកញ្ចប់តូចបណ្ដើរមួយជាន់ហើយមួយជាន់ទៀត ដល់ក្រដាសជាន់ទីប្រាំទើប ឃើញរបស់អ្វីពណ៌ខ្មៅបីដុំ ពិនិត្យមើលទៅទំនងស្គាល់ជាក់ជាខ្មោចដង្កូវក្រៀមក្រញាំ អានហ៊ុនយីទឹងតូច ងាកសួរចូវមុ :

- ប្អូនចូវ ! នេះជាភាគកំប្លែងមានន័យជាដូចម្ដេច ?

ចូវមុភ័យលើសអ្នកសួរ ពោលទាំងរដាក់រដុប:

- ខ្ញុំ . . .ខ្ញុំឥតដឹងអីទេ ។ នែកនេះក្នុងខ្លួនវក្លាវអ៊ីឃើញតែកញ្ចប់តូចមួយនេះ ។

អានហ៊ុនយីយល់ថាវក្លាវអ៊ីយកវត្ថុនោះលាក់កន្លែងណាឬប្រគល់ឲ្យអ្នកដទៃហើយ, ចូវមុ ដណ្ដើមកញ្ចប់ខ្មោចដង្កូវនាំឲ្យអាប់ឱនកិត្តិយសជំរំកាំបិតមាសអស់រលីង ។ គាត់គ្រវាត់ក្រដាស ចោលហើយងាកមកប្រាប់ស៊ុឈីន :

- សូមលោកកុំសើចយំអី, តើហេតុយ៉ាងដូចម្ដេចបានជាលោកជ្រាបអាថ៌កំបាំងនេះ ?

ស៊ុឈីនញញឹម :

- ខ្ញុំចេះតែស្មានទៅណា ! ឥឡូវចាញ់បោកគេទាំងអស់គ្នា, គ្មាននរណាវៃឆ្លាតជាង នរណា ? សុំលាសិនហើយ ។

ស៊ុឈីងគោរពលាចេញពីគុម្ពោតព្រៃដល់វាលស្មៅដែលមានក្អែកក្ងៀនគិតរិយារដ៏ចាំទីនោះបបួល :

-ត្រឡប់ទៅវិញអូន ។

វ៉ុនយូឃើញមុខស្វាមីគាត់យល់ថាមិនបានការអីក៏ដើរតាមប្តី ទៀងជិះសេះបន្តដំណើរទៅទៀត ។ ទីបំផុតគាត់ទ្រាំមិនបានស្រក់ទឹកភ្នែកតក់ៗ ធ្លាលចុងច្រមុះស៊ុឈីងលួងលោមគរិយា:

-កុំតូចចិត្តអី! ក្រុមកាំបិតមាសគឺខកចិត្តដូចយើងដែរ ។ យើងត្រឡប់ទៅឆែកសព្វគ្រាវអ៊ុម្ពងទៀតឲ្យបានមុនគេក្រែងមានផ្លូវណា! ស្រួតដំណើរទៅអូន ។

វ៉ុនយូអស់សង្ឃឹមលើងពីខ្លួន តែមិនហ៊ានជំទាស់នឹងស្វាមីក៏ងក់ក្បាលទ្រើយចាំងរកតែរអួល :

- ទៅរកឲ្យអស់ចិត្តបងចុះ ។

សេះសនិងខ្មៅមួយគូនេះ បោលលឿនណាស់, ថ្ងៃមិនទាន់ត្រង់ផងគេទៅដល់ ហ្វូវជានស្រេច ។ អ្នកភូមិទាំងឡាយមិនទាន់បាត់ភ័យ ឥតហ៊ានបើកទ្វារប្រកបការងារទេ ។ ស៊ុឈីងនាំគរិយាបំផាយសេះសំដៅសព្វគ្រាវអ៊ុ គ្មានឃើញអ្វីក្រៅពីក្មេងម្នាក់អាយុជាង ១០ ឆ្នាំអង្គុយកៀនជញ្ជាំងឡើយ ។

ស៊ុឈីងលោតចុះ ដើរទៅក្រសោបសព្វព្រាណវ៉ូតាអ៊ុ តាំងពីសក់ក្បាលដល់បាតស្បែកជើង វ៉ុនយូដើរចូលគៀមលក់នំនុនសង្កេតគ្រប់កន្លែងម្តងទៀត ។ ពីនាក់ប្តីប្រពន្ធរកសព្វគ្រប់មិនឃើញអ្វីប្លែក ក៏សម្លឹងមុខគ្នាក្ងះៗ អស់សង្ឃឹមដកដង្ហើមយូរ ។ វ៉ុនយូពោលយ៉ាងស្រងូត :

-បងអើយ! មើលទៅយើងពិបាកសងគំនុំនេះណាស់ ។ បងនឿយហត់ប៉ុន្មានថ្ងៃហើយ គួរទៅទីក្រុងមើលល្ខោន ឬ ស្តាប់ចម្រៀងកំសាន្តចិត្តម្តងឬ ?

ស៊ុឈីងស្គាល់ចិត្តគរិយាណាស់, វ៉ុនយូស្នើបែបនេះក្នុងគោលបំណងតែមួយគឺជួយស្វាមីឲ្យបំភ្លេចទុក្ខព្រួយមួយមុខ,គាត់មិនចូលចិត្តភ្លេងភ្លាត់ឬល្ខោនទេ ។ ដោយហេតុយល់យ៉ាងហ្នឹងទើបគាត់យល់ព្រម :

-ត្រូវហើយ, ដើរលេងឲ្យសប្បាយម្តងហើយឆ្លៀតពេលទិញគ្រឿងអលង្ការផង ។

វ៉ុនយូមានរូបសម្ផស្សស្រស់ប្រិមប្រិយមិនចាញ់ក្មេងៗឡើយ ហើយចូលចិត្តតាក់តែងកាយណាស់ មើលមួយភ្លែតគេមិនដឹងថាគាត់មានអាយុច្រើនទេ ស្មានថាក្រមុំ ។ ពេលនេះទឹកមុខគាត់ស្រពោនបន្តិចពោលតិចៗ :

-ដប់បីឆ្នាំហើយ, កូនយើងស្លាប់ចោលទៅបងទិញគ្រឿងអលង្ការឲ្យខ្ញុំច្រើនណាស់, បើប្រមូល

ផ្ដុំមកយើងអាចបើកបានលក់គ្រឿងក្មុងតែងកាយប្លុយបានហាងនេះ ។

អ្នកស្រីពោលដល់ពាក្យកូនយើង « ចិត្តក្នុងហូរហាមចាំងម៉ងដឹងខ្លួន ។ លុះក្រឡេកមើលឃើញ កូនស្ទូមអង្គុយកៀនជញ្ជាំងមុខប្រឡាក់ដីស្រមក ស្លៀកពាក់យ៉ើរយ៉ៃ គាត់នឹកអាណិតកូនសួរណាស់ ដើរទៅជិតក៏សួរ :

- ម្ដាយឯងនៅឯណា, ម៉េចដើរម្នាក់ឯងអ៊ីចឹង ?

ស្ទូមតូចឆ្លើយ :

- ម៉ែខ្ញុំ...ម៉ែខ្ញុំបាត់ហើយ ។

វុនយូដកដង្ហើមធំ លូកហោប៉ៅយកប្រាក់មួយដុំតូចហុចឲ្យ

- ណេះ ! យកលុយទុកទិញអ្វីញុំទៅ ។

បន្ទាប់ពីនោះមកគាត់ដើរទៅរកសេះប្រុងឡើងជិះ ទើបនឹកឃើញសួរម្ដងទៀត :

- អាតូច, ឯងឈ្មោះអីដែរ ?

កូនស្ទូមឆ្លើយ :

- ខ្ញុំ...ខ្ញុំឈ្មោះ « ក្ដែងកពូជ » ។

ស៊ុឈីងហួសចិត្តពោលម្នាក់ឯង :

- វាជាក្មេងល្បីល្បីគួរអាណិតណាស់តើ !

វុនយូបន្ទរ :

- ហ្នឹងហើយ, អាណិតគ្នាណាស់ ។

ពីរនាក់ប្ដីប្រពន្ធ ញាក់សេះបេញដំណើរទៅទុកស្ទូមតូចនៅម្នាក់ឯងម៉ងៗ ។ កូនស្ទូមតូចនេះ ក៏យកនឹងរូតាវអ៊ីសន្ទប់បាត់ស្មារតីមួយយប់ទើបភ្ញាក់ទើបដឹងខ្លួន ។ លុះបើកភ្នែកឃើញរូតាវអ៊ី ប្រឡាក់ឈាមពេញប្រាណក៏ភ័យញ័រចំរេចភ្នែករហូតលង់លក់ចាំងរវើរវាយ, ក៏ផេកភ្ញាក់ៗតាំងពីព្រឹក រហូតដល់ថ្ងៃត្រង់ទើបរត់ទៅពួនកៀនជញ្ជាំងចាំគេច្រកបេញដំណើរគេទៅទៀត ។ ឃើញស៊ុឈីង ទាញសពរូតាវអ៊ីវាខំសម្ងំផុតបាំងគំហើកខ្លួនទេ លុះវុនយូហុចដុំប្រាក់ឲ្យទើបវាអន់ភ័យ ។ ស្ទើរតែ ចេញទៅអស់ទើបវានឹកឃើញសំដីអ្នកស្រីដែលប្រាប់វាឲ្យទុកលុយទិញនំវានឹកថា:

- ទិញនំអីទៀត បើមាននំនៅដៃស្រាប់ហើយ ?

ភ្លាមនោះពោះវាគ្រូកគ្រូកៗ វាហាមាត់ទាំងរំភើបស្រាប់តែឮស្គរតើបសឹងបាក់ធ្មេញប៉ះអ៊ើរីងដូចជុំដែក ៗ ស្អុយក្លូចឈឺណាស់ខ្ជាក់នំដាក់លើបាតដៃមើលជុំដែកខ្មៅព្រីក ដែលកប់ក្នុងនំ ដៃម្ខាងស៊ីនំឃ្នុម ១ ដៃម្ខាងលើកឈើគាស់ជុំដែកមួយបន្ទះមើលចុះឡើង តាមរបៀបក្មេង ៗ អស់នំពីដៃទើបវាសំឡឹងគំទេចនំ ដែលខ្មោចរូតារ៉ូប្រាប់ពេលហើយផ្តើងសួរៈ

-នំដែលខ្មោចកាន់ប្រាប់លេងហើយយើងស៊ីបានដែរហ្នឹ?

ខណៈនោះឮសម្លេងមនុស្សស្រែកព្រមគ្នាលើក្បាលវាថាៈ ឡោមព័ទ្ធឲ្យគ្រប់ទិសរុំយ !

ក្មួនស្នួមនឹកឆ្ងល់ថាហេតុអីមានសម្លេងមនុស្សលាន់មកពីលើ?

វាងើយមើលឃើញមនុស្សបីនាក់ពាក់អាវសឈរលើដំបូល រួចវាឮសន្ទឹកខ្យល់វឹប ១ ក្រោយខ្នងៗ វាងាកទៅឃើញជនប៊ូនាក់ទៀតពាក់អាវសដែរ កាន់ដាវគ្រប់ដៃដើរចូលមកចាំងសង់ខាងវាភ័យញ័រ ហាមាត់លែងរួច ៗ បន្ទាប់មកទៀតឮជើងសេះគុបៗពីចម្ងាយព្រមទាំងសម្លេងច្បាស់ថៃសស្រែកថាៈ

-អូ ! សុទ្ធតែមិត្រខាងក្នុងកកកក ! អានហ៊ុនយ៉ីខ្ញុំសូមជម្រាបសួរ !

ក្នុងមួយនាទីនោះសេះលឿនមួយផាយមកដល់ជនម្នាក់ជុះពុកមាត់ស្រមាម លោតផ្លោតចុះពីបណ្តោយឲ្យសេះលឿនបោលតទៅទៀតព្រងើយ ៗ ក្នុងពេលជាមួយគ្នានោះជនអាវសនៅលើដំបូលផ្ទះបង្ហើរខ្លួនចុះមកប្រឹបៗហូតដាវសស្វាគមគ្រប់ៗគ្នា ៗ ជនម្នាក់ហាឧដ់មាំពោលមុនគេៈ

- លោកម្ចាស់ជំរាប់បិតមាសឬ ? សុំគោរព !

ពោលផងមិចភ្នែកឲ្យសញ្ញាទៅសហការីមួយរូបដែលឈរក្រោយខ្នងអានហ៊ុនយ៉ីផង ៗ

ត្បិតអានហ៊ុនយ៉ីប្រកួតចាញ់ស៊ីឈើងគាត់តូចចិត្តណាស់ ច្បូតពុកមាត់គិតថា :

- ប្តីប្រពន្ធស៊ីឈើងត្រឡប់ទៅគូបិហូវជានធ្វើអីទៀត ? អួប្រហែលគេទៅផែកគេរកវត្ថុនោះម្តងទៀតឬ ? យើងចាញ់ស៊ីឈើងមែនតែគ្មានអ្វីឃាត់ឃាំងយើងមិនឲ្យទៅរកជាលើកទីពីរទេ, នរណារកឃើញអ្នកហ្នឹងមានសំណាង ៗ

សម្រេចចិត្តបែបនេះទើបអានហ៊ុនយ៉ីលោតផែលលើខ្នងសេះ ពណ៌លឿងទៅតាមក្រោយតែសេះគាត់បោលចាញ់សេះសនិងខ្មៅរបស់ប្តីប្រពន្ធស៊ីឈើងហើយគាត់មិនបង្វែរវាផងទើបទៅដល់ទីកន្លែង ក្រោយ … ៗ គាត់មើលពីចម្ងាយឃើញស្រមោលស…បុនលើដំបូលផ្ទះ ក៏គាត់យល់ថាជាសិស្សនៃ … ដែល ៗ គាត់មិនដឹងថាប្តីប្រពន្ធស៊ីឈើងចាកចេញពីទីនេះបាត់ទេ ! ក្រឡេក

ឃើញទឹកមុខជនពាក់អាវសខេបមាំទាំគាត់ស្មានថាគេប្រុងលបវាយឆ្មក់ប្តីប្រពន្ធស៊ុំឈីនគឺ ស្រែកពីចម្ងាយ ប្រាជ្ញាប្រាប់អ្នកមានគុណឲ្យដឹងខ្លួនមុន ។

អានហ៊ុនយីមកដល់ទីកន្លែងមិនឃើញប្តីប្រពន្ធស៊ុំឈីនថែរដារ ឃើញជនពាក់អាវស ៧ នាក់ឈរព័ទ្ធ ក្មេងកំព្រាម្នាក់នៅវិញ គាត់ឆ្ងល់ណាស់ ចំសង្កេតពិនិត្យក្មេងតូចយ៉ាងយកចិត្តទុកដាក់ គ្មានឃើញសញ្ញាអ្វីគួរឲ្យសង្ស័យសោះ ។ លុះឃើញជនអាវសម្នាក់មិចក្លែកជាសញ្ញា គាត់មើលកូនសម្លាប់ម្តងទៀតៗ ក្រៅពីខោអាវហែក មុខមាត់ប្រឡាក់ដីស្រមក គាត់ឃើញវាកាន់បន្ទះដែកមួយខ្មៅព្រឹក ដូចជា « ផ្ទាំងបញ្ជាសំរិទ្ធ ល្បីល្បាញក្នុងពិភពគុន ។

ក្រោមនោះជនអាវសប្អូនគាត់លោសដាវប្រុងស្ទុះទៅរកក្មេងកំព្រា, អានហ៊ុនយីមិនបង្អង់យូរក៏ដកកាំបិតបញ្ចេញស្មៀត រត់ជុំវិញក្មេងម្តងកាច់ស្តាំម្តងឆ្វេង ចាក់ទៅមុខផងទៅក្រោយផងការពារជុំជិតឥតឲ្យសន្ទះដាវណាមួយចូលចុះ ។ កូនសម្លាប់ឃើញមនុស្សធំបញ្ចេញអាវុធតាមកេមរាហើយត្រូវឡប់កាំបិតត្រជាក់ស្រេបព្រមទាំងចាំងក្លែកផងគឺស្រែកយំរាំ! ជនពាក់អាវសទាំង ៧ ត្រឹវដាវព្រមគ្នាបង្កើតជាវង្វង់មូលមួយក្តីក្លួតព័ទ្ធកូនសម្លាប់និងអានហ៊ុនយីជុំជិត ។

ចំផ្លាភាពដ៏ចម្លែកនេះគួរគយគន់ណាស់ វង្វង់ដាវសស្វាចដែលមានទ្រង់ទ្រាយធំរុំដង្កូវតូចមួយដែលដះកាស្ទើរពណ៌លឿងដ៏ចិញ្ចាច គឺពណ៌នៃកាំបិតមាសដែលអានហ៊ុនយីគ្រវាសយ៉ាងញាប់ ដើម្បីការពារដៃ..ភីពួកជនពាក់អាវសកុំឲ្យចិតទៅជិតកូនសម្លាប់នោះឯង ។

ជនអាវសធ្វើសញ្ញាដាក់គ្នារួមកម្លាំងវាយលុកយ៉ាងខ្លាំងក្លាក្នុងបំណងបង្រួញវង្វង់ហ៊ុមព័ទ្ធ ឲ្យកាន់តែតូចទៅ ១ អាលឹងចាប់យកកូនសម្លាប់ឲ្យបានមុនគេ ។ ពេលនេះស្រាប់តែលាន់ឮស្នូរជើងសេះមកកាន់តែជិតឡើង ។ ដោយលេចអាជាឈ្មៅមួយដាយយ៉ាងលឿនមកពីចម្ងាយ ។ គឺប្តីប្រពន្ធស៊ុំឈីនបានត្រឡប់មកវិញ ។

ដំរូតគឺប្តីប្រពន្ធទាំងគូនេះ ចាកចេញពីភូមិនេះមិនឆ្ងាយប៉ុន្មានក៏ប្រទះឃើញសញ្ញាអាថ៌កំបាំងនៃពួកក្នុងទឹកកក ។ គេនឹកសង្ស័យក៏នាំគ្នាវិលមកវិញព្រមពេលដែលឆាកប្រយុទ្ធចាប់ផ្តើមរវាងមេដំរីកាំបិតមាសនិងពួកជនអាវសនេះ ។ ស៊ុំឈីនស្រែកឃាត់:

– មិត្តខាងក្នុងទឹកកកនិងមេដំរីកាំបិតមាសឈប់សិន ! សុខ្ខៃគ្នាឯងទេ យើងទាំងនិយាយគ្នាបានទេតើ !

ពពួកសិស្សភ្នំទឹកកក បញ្ឈរជាវនៅស្ងៀម, ឈប់វាយលុកទៀត តែគេនៅតែព័ទ្ធកូនស្ទូមនឹងអានហ្គុយ៉េដដែល ។

ស្រាប់តែប្ដីប្រពន្ធស៊ីឈីងលាន់មាត់ « យី » ព្រមគ្នា ។ ខុំៈខំ ! កូនស្ទូមកាន់បន្ទះអ្វីខ្មៅព្រិចនៅដៃ គឺវត្ថុដែលជាទីដៅរបស់ខ្លួនទេដឹង ?

ស៊ីឈីងយល់ថា អានហ្គុយ៉េពិតជាមិនខ្មាសខ្លួនទេ ហើយពពួកខាងភ្នំទឹកកកក៏មិនអាចរាំងខ្លួនបានដែរទើបពោលទៅកាន់កូនស្ទូមថា :

- ប្អូនតូច ! ឯងកាន់អ្វីនៅនឹងដៃហ្នឹង ? ឲ្យបងសុំមើលផងបានទេ ?

ជនអាវសជាមេគេពោលកាត់ :

- លោកស៊ី ! ពួកខ្ញុំបានឃើញវត្ថុនោះមុនលោកណា៎ !

វុនយូឆ្លើយជំនួសប្ដី:

- បងទិន ! បងសួរប្អូនតូចនេះមើលថាដុំប្រាក់នៅក្បែរយើងវានោះជាប្រាក់ដែលខ្ញុំបានឲ្យវា មែនឬទេ ?

សំដីនេះបញ្ជាក់ថានាងបានឃើញកូនស្ទូមមុនដោយបានតាំងឲ្យប្រាក់វាមួយដុំផង ! .

ជនពាក់អាវសមាឌធំនេះជាអ្នកក្លាហានជាងគេទីពីរនៃភ្នំទឹកកក ។ គាត់ឆ្លើយវិញ:

- លោកស្រីស៊ី ! ប្រហែលជាលោកទាំងពីរបានឃើញប្អូនប្រុសនេះមែន តែចំពោះ "បញ្ជាដែកសំរិទ្ធ" នេះវិញគឺពួកបងប្អូនខ្ញុំទេដែលបានឃើញមុន !

គ្រាន់តែឮពាក្យ "បញ្ជាដែកសំរិទ្ធ" ភ្លាម ស៊ីឈីងវុនយូនិងអានហ្គុយ៉េ ភ្ញាក់ព្រើតនឹងថា:

-នេះពិត "បញ្ជាដែកសំរិទ្ធ" មែន ! ឯសិស្សភ្នំទឹកកកប្រាំមួយនាក់ទៀតក៏បញ្ចេញទឹកមុខភ្ញាក់ផ្អើលដែរ ។

តាមពិតពួកគេទាំងប្រាំពីរ ពុំទាន់បានពិនិត្យមើលបន្ទះដែកក្នុងដៃកូនស្ទូមនោះ ឲ្យបានច្បាស់លាស់នៅឡើយ តែដោយឃើញប្ដីប្រពន្ធស៊ីឈីង និងមេដំរកាំបិតមាសមានអាការះភ្ញាក់ដូច្នេះ ក៏សន្មត់ថា "បញ្ជាដែកសំរិទ្ធ" ទៅ !

ចំណែកប្ដីប្រពន្ធស៊ីឈីង និង អានហ្គុយ៉េ ក៏សន្និដ្ឋានថា ពិតជាវត្ថុដែលគេចង់ស្វែងរកនោះមែនដោយអាងទៅលើការសន្មតអឡាញ់មិញនៃពួកសិស្សភ្នំទឹកកក ដែលគេធ្លាប់ស្គាល់ថាជាអ្នកមានការ

ពិសោធន៍ច្រើន ។

អ្នកគុននិយមទាំងដប់នាក់មានចំណងស្អូតគ្នាចំពោះរឿងនោះ ម្ល៉ោះហើយគេក៏ហុចដៃស្ទើគ្នាដោយពោលថា :

- ប្អូនប្រុសឡេបនីមក !

ពួកគេទាំងអស់សុទ្ធតែមានការក្រេវក្រែងគ្នាទៅវិញទៅមក, គេមិនហ៊ានស្ទុះទៅដណ្ដើមទេ ហើយដឹងថាបើខ្លួនធ្វេសប្រហែសត្រូវច្បាស់ជាវាយទុកខ្លួនពុំខាន ។ គេនឹកសង្ឃឹមរៀងខ្លួនថាកូនស្វាមនឹងប្រគល់បន្ទះដែកមកឲ្យខ្លួន ។ ឯកូនស្វាមវិញគ្មានដឹងខ្លួនសោះថាពួកអ្នកក្លាហានទាំងនេះមានបំណងលើបន្ទះដែកតូចដែលសឹងតែធ្វើឲ្យបាក់ធ្មេញខ្លួននោះ ។ ពេលនេះវាឈប់យំហើយតែទៅ?កក្តុកចិត្តសំពោរលើងរលោងក្នុងអាការៈមិនយំទំនងទៀត...

ខណៈនោះស្រាប់តែឮសម្លេងមួយដ៏ខាប តែធ្ងន់បន្ទឺថា :

- ឲ្យមកយើងវិញ !

មិនទាន់ចប់សម្រែកនេះផង ស្រមោលមនុស្សម្នាក់លោតចូលមកក្នុងហ្វូងមនុស្ស លូកដៃកញ្ឆក់យកបន្ទះដែកពីកូនស្វាមក្មេង ។ សម្រែកច្រួលច្របល់ កំណាន់ក្ដៅឡើង :

- លើកដៃ ! ... ធ្វើអី ? .. អស្ចារ្យមែន ! អាចង្រៃ !

ផ្ទះហ្វាងព្រោះតែពិធីកាប់គមាសមួយវាយលុកទៅរកស្រមោលនោះព្រមគ្នា ។ អានហ៊ុងយើងនៅជិតកូនស្វាមជាងគេ, គាត់ត្រូវសំពាំបិតរឹបសំពត់ក្លូលជននោះ ។ ពួកសិស្សក្មេងកកកញ្ចាប់ហាក់ហ៊ឹកហ៊ឺន ជាយូរមកហើយ ផ្ទះហ្វាងទាំងប្រាំពីរវាយដំពាក់ហ៊ឹសសម្រុកព្រមគ្នាសំដៅដីពងប្រាំពីរកន្លែងលើខ្លួនជនអាថ៌កំបាំង ។ ពេលទៅនោះជាជននោះទាំងកាត់យ៉ាងណាក៏គេបមិនផុតដែរ ។ ចំណែកស៊ុយឈឹង និងវ៉ុនយូដោយមិនស្គាល់ជនអាថ៌កំបាំងជាមនុស្សប្រភេទណា ទើបមិនទាន់ប្រើស្នៀតកាចសាហាវ ។

ក្ដុងសូរតែពីងចមិនជាចស្វូរ, ដៃទាំងពីរនៃជននោះត្រូវគ្រវាត់ហ៊ើសអស្ចារ្យវិស័យផ្ទុកបន្ទោរ ។ មួយប៉ប្រិចភ្នែកសោះកាំបិតមាសអានហ៊ុង និងផ្ទះហ្វាងទាំងប្រាំពីរនៃសិស្សក្មេងកកកត្រូវជននោះដណ្ដើមយកបានអស់ ។ ឯស៊ុយឈឹង និងវ៉ុនយូឈឺស្លឹកដីពងកដៃសឹងតែរបូតដាវតែគេប្រញាប់នាំគ្នាស្ទុះលោតថយក្រោយទាន់ ។ ស៊ុយឈឹងកនឹកមុខស្លឹកស្លាំង ឯវ៉ុនយូមុខឡើងក្រហមឆ្អិន ។

❦

## វគ្គទី ៣

## ម្ចាស់បញ្ហាដែកសំរិទ្ធ

វិជ្ជាគុនដាវរួមនៃប្ដីប្រពន្ធម្ចាស់គូមិសាំងស៊ូអាចចាត់ទុកថាជាស្នៀតដ៏វិសេសវិសាល , មិនងាយអ្នកណាទប់ទល់រួចឡើយ ។ តែអម្បាញ់មិញ , ជនចំឡែកគ្រាន់តែយកម្រាមផ្ទាត់ផ្លែដាវសោះ គេទាំងពីរក៏វិះរបូតដាវពីដៃទៅហើយ ។ នេះជាព្រឹត្តិការណ៍ដ៏កម្រ ដែលអ្នកទាំងពីរមិនធ្លាប់បានជួបប្រទះសោះនៅឡើយ ។ ស៊ីឈ័ងនិងវុនយូភ្ញាក់ភ័យជាខ្លាំង ។ គេបែរសង្កេតមើលទៅជនអាថ៌កំបាំងឃើញកាំបិតមាសនិងផ្លែដាវទាំងពីរ ដោតជាប់ក្នុងដីជុំវិញខ្លួនជននោះ ។ ជនចម្លែកមានសំលៀកបំពាក់ខៀវ , ផុះពុកមាត់ខ្ចី ៗ , អាយុប្រមាណជា ៤០ ឆ្នាំ ហើយមានទឹកមុខពណ៌ខៀវ ។ ជនអាវខៀវសប្បាយរីករាយណាស់នឹងជោគជ័យរបស់គេ ។ ពេលនោះស៊ីឈ័ងនឹកឃើញដល់មនុស្សម្នាក់ក៏ស្រែកភ្ញាក់សម្ដីថា :

–លោកប្រហែលជាម្ចាស់នៃបញ្ហាដែកសំរិទ្ធនេះឬ ?

ជននោះសើចហ៊ុះៗតប :

–ដាវខ្មៅ-សនៃគូមិសាំងស៊ូល្បីឈ្មោះក្នុងពិភពគុនយូរហើយ ថ្ងៃនេះបានឃើញជាក់នឹងភ្នែកពិតជាអស្ចារ្យមែន ។ អម្បាញ់មិញយើងប្រើកម្លាំងតែ១ភាគទប់ទល់នឹងមិត្តទាំង៨ខាងណេះបាន យ៉ាងគួរ រីឯ៩ភាគទប់ទល់នឹងឯងពីរនាក់ប្ដីប្រពន្ធនៅតែមិនអាចដណ្ដើមយកអាវុធបានទៀត ។ ហ៊ឺ ! មើលទៅវិជ្ជាផ្ទាត់ម្រាមរបស់យើងប្រហែលជាមិនទាន់ហាត់រៀនដល់កំពូលទេ ? យ៉ាងហោចណាស់ក៏ត្រូវចំណាយពេលដប់ឆ្នាំទៀតដែរ ។

ស៊ីឈ័ងស្ដាប់ហើយលែងសង្ស័យទៀត , ប្រញាប់ពោលថា :

– យើងពីរនាក់ប្ដីប្រពន្ធមកកាន់ទីនេះទោះជាគោលបំណងមិនទាន់បានសម្រេចក៏ដោយ តែមាននិស្ស័យបានជួបលោក ក៏ជាការប្រសើរម្យ៉ាងដែរ ។ វិជ្ជាដ៏ទន់ខ្សោយនៃយើងទាំងពីរ មិនគួរបើយកមកសម្ដែងជូនលោកមើលសោះ ថ្ងៃនេះលោកបានទទួលយកបញ្ហាដែកសំរិទ្ធដោយផ្ទាល់ដៃ គឺជារឿងមួយគួររីករាយណាស់ ។

ចំណែកសិស្សនៃក្រុមភ្នំគកកស្ដាប់ចប់សំដី ស៊ីឈ័ង ក៏នឹកត្រិះរិះក្នុងចិត្តថា "ជនអាវខៀវពិតជាម្ចាស់បញ្ហាដែកសំរិទ្ធ ឈ្មោះ សែយាន នោះឬ ? មើលទៅមុខមាត់គេគ្មានអ្វីគួរឲ្យចំឡែកសោះ មិន

សមជាកំពូលអ្នកក្លាហានដែលអ្នកគ្រូនិយមខ្លួនទៅ តែឥឡូវគេគ្មានទេ ។ អ្នកមួយស្នៀតអម្បាញ់មិញគាត់ដណ្តើមយកការុតពីពួកយើងបានទាំងអស់ ប្រហែលគ្មានអ្នកទី ២ ណាប្រកបដោយក្រមិតយុទ្ធសិល្បៈ ខ្ពស់ដល់ម្លឹងទេ ។ នឹកដូច្នេះហើយអ្នកទាំង៧មើលមុខគ្នាធ្វើភ្នែកឡិងឡង់ ដោយពុំមានអ្នកណាចេញស្តីអ្វីឡើយ ។ គានហ៊ុនយ៉េលើកដៃប្រណម្យពោលថា :

– អម្បាញ់មិញខ្ញុំមានការឆ្គាំឆ្គងចំពោះលោក, សូមមេត្តាអភ័យទោសផងចុះ ។

ផនគាវទៀវពិតជាវិសិយាននៅក្នុងមិនមែន ។ គាត់សើចក្អាកក្អាយពោលថា :

– បើតាមទំនៀមទំលាប់របស់យើង ពួកឯងប្រើការុតកាប់សំពងលើខ្លួនយើងដូច្នេះ យើងត្រូវតែសងសឹកជាដាច់ខាត ! ឯងប្រើកាំបិតមាសកាប់ស្នាក្មេងយើង យើងក៏ត្រូវតែយកកាំបិតមាសកាប់ស្នាក្មេងឯងវិញដែរ ។

គាត់និយាយដល់ត្រង់ណេះ ក៏ចាប់បន្ទះដែកដែលនៅក្នុងដៃក្មេងបោះឡើងទៅលើ ហើយក្រវ៉ងយកវិញទើបបន្ត:

– ប៉ុន្តែថ្ងៃនេះ យើងសប្បាយរីករាយណាស់· ម្ល៉ោះហើយគំនុំមួយកាំបិតនេះសូមកត់ត្រាទុកសិនចុះ ! ឯចំណែកឯងយារកាំបិតចាក់ច្រូងយើង ឯងចាក់ដីពចក្តៅយើង ឯងចាក់បង្កេះក្មេងយើង ឯងចាក់កំភួនជើងយើង . . .

គាត់ពោលបណ្តើរលើកដៃចង្អុលសិស្សទាំង៧នៃក្តិចកកបណ្តើរ ។ ពួកសិស្សទាំង៧ឃើញគាត់ចាំយកចាំស្នៀតដែលពួកខ្លួនចាក់ស្រោចទៅលើគាត់យ៉ាងក្បោះក្បាយ ដោយគ្មានភ័ន្តច្រឡំដូច្នេះ ក៏ភ័យស្ញប់ជាខ្លាំង ។ ក្នុងមួយបំប្រិចភ្នែកសោះយានទីគាត់អាចមើលស្គាល់ស្នៀតគុន នៃអ្នកពលគ្នា ហើយចាំយ៉ាងជាក់លាក់ទៀតផង ។ គាត់ពោលបន្តទៀត:

–គំនុំទាំងនេះត្រូវកត់ទុកក្នុងបញ្ជីសិន ចាំកាលណាយើងមានចិត្ត «មិនស្លូវស្រួល» សឹមតាមទារបំណុលវិញ ។

សិស្សក្តិចកកម្នាក់ដែលមានមាឌធាបបានស្រែកខ្លាំងៗថា :

–ពួកយើងមានវិជ្ជាខ្សោយមែន, បើចាញ់ក៏ចាញ់ទៅចុះ ឯងមិនបាច់ពោលចំអកដូច្នេះទេ ! ហើយមិនចាំបាច់កត់បញ្ជីអ្វីទេ ជំរះគ្នាឲ្យហើយទៅ !

(នៅមានត)

ដំកល់ទុកតាមលេខ ២៨៨ ចុះថ្ងៃទី ១៨ - ៥ - ៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers